## បេសកកម្មយើង

បង្កើតបរិយាកាសមួយ លើកទឹកចិត្តយុវជនខ្មែរជំពិសិដ្ឋជំនាន់ក្រោយ ឲ្យមានលទ្ធភាពរៀនសូត្របានខ្ពស់ ដើម្បីលើកកម្ពស់ជីវភាពខ្លួននិងអ្នកដទៃ ឲ្យប្រសើរឡើង និងធ្វើឲ្យប្រទេសជាតិបានសម្បូណ៌រុងរឿង។


ព្យាយាមសាបព្រោះបណ្ដុះដាំ បាចគ្រាប់ពូជត្រាំទៅក្នុងថ្នាល
សម្រាំងសំណាបស្រស់ត្រកាល ផ្ដុងផ្ដើមកើតកាលវាលគុម្ពអើយ ។

## គោលដៅយើង

បណ្ដុះបណ្ដាលសង្គមនៅប្រទេសកម្ពុជា ឲ្យប្រកបដោយវិជ្ជាកោសល្យមួយ ដោយ

- ផ្ដល់លទ្ធភាពដល់និស្សិតដែលខ្វះការផ្គត់ផ្គង់ទាំងឡាយ ឲ្យបានសម្រេចការសិក្សាដល់ថ្នាក់ខ្ពស់បំផុត។
- បណ្ដុះគំនិតមនសិការផ្ទាល់ខ្លួនដល់យុវជន តាមរយៈការគួរសម និងការគោរពរាប់អានគ្នា ទៅវិញទៅមក។
- ធ្វើជារូបមន្តគម្រូមួយ ដើម្បីបង្កើនសហការជាមួយគ្នា រវាងអ្នកទំនុកបម្រុង និងនិស្សិត។

## មូលនិធិយើង

ជាអង្គការមនុស្សធម៌ឥតយកកម្រៃមួយ ស្របតាមច្បាប់លេខ 501(c)(3) សម្រាប់ទ្រទ្រង់ប្រសើរភាពការសិក្សា។ **មូលនិធិ** នេះ ជួយផ្ដុងផ្ដើមនិស្សិតខ្មែរ ឲ្យរៀនសូត្របានយ៉ាងឧត្ដម ទទួលអប់រំវិជ្ជាជីវៈ និងមានអភិវឌ្ឍន៍ខាងផ្នែកដឹកនាំ ទៅអនាគត។

*ពលរដ្ឋ ជាសរសរទ្រទ្រង់ជាតិ។*

យើងទាំងអស់គ្នាអាច **ផ្ដល់លទ្ធភាពសិក្សាស្មើភាពគ្នា** ឲ្យបានសម្រេចជាស្ថាពរ ព្រោះយើងជឿថា "*សាមគ្គីជាកម្លាំង ហើយវិជ្ជាជាអានុភាព*" ។

សូមឧបត្ថម្ភ មូលនិធិខ្មែរសម្រាប់ការសិក្សា ដោយចូលរួមជាមួយក្រុមយើង នៅ

http://groups.google.com/group/CEEFoundation?hl=en

និង/ឬសូមសទ្ធាជ្រះថ្លាធ្វើអំណោយ (payable to CEE Foundation) មក

**CEE Foundation/Treasurer**
**9845 Canal Road**
**Montgomery Village, MD 20886**

សូមអានវិបសាយយើង

www.CEEFoundation.org

មូលនិធិខ្មែរសម្រាប់ការសិក្សា

# Cambodian Education Excellence Foundation



## ផ្ដល់លទ្ធភាពសិក្សាស្មើភាពគ្នា

ជួយលើកទឹកចិត្ត និងផ្ដល់មធ្យោបាយដល់ និស្សិតខ្មែរក្រីក្រ ដែលរៀនពូកែ គួរទទួលការផ្គត់ផ្គង់ ហើយដែលមានគុណធម៌ប្រពៃ សេចក្ដីសុចរិត ព្រមទាំងគោលបំណងពិតប្រាកដ ក្នុងវិជ្ជាជីវៈ ឲ្យមានឱកាសបានចូលរៀនដល់ថ្នាក់ឧត្ដមសិក្សា។

# សិទ្ធិ និងគុណសម្បត្តិ សម្រាប់ អាចទទួលអាហារូបករណ៍

## និស្សិតខ្មែរណា

- បានសម្រេចការសិក្សាយ៉ាងប្រសើរ
- មកពីគ្រួសារខ្សត់ខ្សោយ
- មិនជាប់សាច់ញាតិនឹងសមាជិកគណៈកម្មាធិការជ្រើសរើសនៃ **មូលនិធិ**
- មិនបានទទួលជំនួយគ្រប់គ្រាន់ពីបុគ្គល ឬអង្គការដទៃ
- មានគុណសម្បត្តិយ៉ាងនេះ
  - គួរឲ្យទុកចិត្តបាន
  - មានស្មារតីទទួលខុសត្រូវ
  - មានភាពចេះគោរពគួរសម
  - មានភាពជាពលរដ្ឋល្អ
- នឹងចូលរៀនវិជ្ជាស្ថានខ្មែរពេញពេល
- នឹងរក្សាការសិក្សាឲ្យវិសេសឧត្តម
- ផ្តល់លិខិតគាំទ្រពាក្យសុំចំនួនបីច្បាប់ ពីសាស្ត្រាចារ្យ និងអ្នកដទៃណាដែលមិនជាប់សាច់ញាតិនឹងនិស្សិតដែលដាក់ពាក្យសុំ
- ផ្តល់បទនិពន្ធមួយ មាន ២០០០ពាក្យ រៀបរាប់ពីការសម្រេចចូលរៀនឧត្តមសិក្សា និងពីគោលបំណងអាជីព
- ផ្តល់សេចក្តីការណ៍ពីមុខវិជ្ជាសិក្សា មក **មូលនិធិ** ជារៀងរាល់ចុងឆមាស។
- បំពេញសេចក្តីត្រូវការផ្សេងៗទៀត ដែលចែងដោយ **មូលនិធិ**។

CEE Foundation FlyerKhmer 0808

*"ប្រជាជាតិមួយ ដូចជាសង្គមមួយ ត្រូវបង្កើតពលរដ្ឋម្នាក់ប្រកបដោយសីលធម៌ ហើយសមាជិកម្នាក់ៗចេះទទួលខុសត្រូវផ្ទាល់ សម្រាប់សង្គមរបស់ខ្លួន"។*

Thomas Jefferson



## ជាព័ត៌មានបន្ថែម សូមទាក់ទង

- ខៅ សំរ៉ង, នូវយ៉ក សរអា 516-974-9616 skchao@CEEFoundation.org
- បាវ បេន, វៀរហ្ស៊ីនីញ៉ា សរអា 703-670-0854 bbao@CEEFoundation.org
- តាន់ ចៀប, កម្ពុជា 012-495-495 ctan@CEEFoundation.org
- ជាន ម៉េងលី, តិចសាស់ សរអា 972-669-0006 mchean@CEEFoundation.org
- គិមអាន សេរី, ម៉ារីឡិន្ត សរអា 301-330-4935 skiman@CEEFoundation.org
- ស្មៀដ ចិន្តា, កាលីហ្វនីញ៉ា សរអា 408-930.3333 csmead@CEEFoundation.org
- ទេព សោភា, វៀរហ្ស៊ីនីញ៉ាសរអា 571-218.9513 step@CEEFoundation.org
- ថ្លាង អេរីក, កាលីហ្វនីញ៉ា សរអា 415-827-2275 ethlang@CEEFoundation.org
- អ៊ុំ សង់អុន, កម្ពុជា 012-905-236 soum@CEEFoundation.org
- ឈ ហ្សង់បាប់ទីស្ត, បារាំង 09 5173 4269 jbchhuor@CEEFoundation.org
- យុន ប៊ុនគន, កាណាដា 514-494-1781 byun@CEEFoundation.org

**វិបសាយយើង** *www.CEEFoundation.org*

**ក្រុមពិភាក្សាយើង** *http://groups.google.com/group/CEEFoundation?hl=en*

# គោលដៅសំខាន់របស់យើង

- បង្កើតប្រាក់ឧបត្ថម្ភអាហារូបករណ៍ទូទៅមួយ សម្រាប់ឧត្តមសិក្សា។
- បង្កើតប្រាក់ឧបត្ថម្ភអាហារូបករណ៍ពិសេសមួយ សម្រាប់និស្សិតដែលមានគុណសម្បត្តិស្របតាមតម្រូវការកម្រឹតដោយបុគ្គល ឬក្រុមនានា។
- បង្កើតប្រាក់ឧបត្ថម្ភអភិវឌ្ឍន៍ការសិក្សាឯទៀត ដោយឡែកពីអាហារូបករណ៍។

### *កំណត់ហេតុ*

*"នៅឆ្នាំ ២០០៥ ក្នុងចំនួននិស្សិត ៤៧.៨៧០នាក់ដែលប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សា ៣៤.១៧៤នាក់ (៧១ %)បានប្រឡងជាប់ ប៉ុន្តែនិស្សិតចំនួនត្រឹមតែ ២.៤១២នាក់(៧%)ប៉ុណ្ណោះ ដែលបានទទួលអាហារូបករណ៍ចូលរៀនឧត្តមសិក្សាបាន។"* †

នៅឆ្នាំ ២០០៧ យើងបានផ្តល់អាហារូបករណ៍ ឲ្យនិស្សិតចំនួន៣០នាក់។ ទៅអនាគត យើងបម្រុងផ្តល់អាហារូបករណ៍ដូចតទៅ

### ក្នុងឆ្នាំ ២០០៨

ផ្តល់អាហារូបករណ៍ទូទៅចំនួនយ៉ាងតិច ១០០ ហើយនីមួយៗមានចំនួនទឹកប្រាក់

- ១០០ដុល្លា សម្រាប់សៀវភៅ
- ២០០ដុល្លា សម្រាប់លំនៅ និងអាហារ

### ក្នុងឆ្នាំ ២០០៩ និង ឆ្នាំជាបន្ត

ក្នុងមួយឆ្នាំ ផ្តល់អាហារូបករណ៍ទូទៅ យ៉ាងតិច ១០០ ហើយនីមួយៗមានចំនួនទឹកប្រាក់

- ១៥០ដុល្លា ឬច្រើនទៀត សម្រាប់សៀវភៅ
- ៣០០ដុល្លា ឬច្រើនទៀត សម្រាប់លំនៅ និងអាហារ

† http://cambodiastrategicinsight.blog4ever.com/blog/lirarticle-17061-49569.html